ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ ១០៣/០៧ រ.ប.ក/អជបគញ

*រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែតុលាឆ្នាំ២០០៧*

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ៩ខែ ឆ្នាំ២០០៧

របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

(០៦/១២/២០០៦-២៥/៩/២០០៧)

## I / សភាពការណ៍គ្រឿងញៀន

### ១.ការផលិត និង ការជួញដូរ

**-ការផលិតគ្រឿងញៀនសំយោគATS**

រយៈពេល៩ខែកន្លងមកនេះ ការផលិតកែច្នៃគុណភាព និង ផលិតក្លែងក្លាយ នូវប្រភេទគ្រឿងញៀនសំយោគ**ATS** បានបន្តកើតមាននៅក្រុងភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កណ្តាល ។ ការផលិតធ្វើឡើងដោយដៃតាមរយៈពុម្ពកែច្នៃតូចៗ និង ពុម្ពគៀបគ្រាប់ថ្នាំដែលប្រើដោយម៉ូទ័រធុនតូច ។

ទន្ទឹមនឹងការផលិតដូចលើកឡើងខាងលើ ក្នុងរយៈពេល៩ខែនេះក៏លេចចេញនូវសញ្ញានៃការប៉ុនប៉ងយកកម្ពុជាធ្វើជាទីតាំងផលិតគ្រឿងញៀនសំយោគក្នុងទ្រង់ទ្រាយធំដោយក្រុមឧក្រិដ្ឋជនបរទេស ប៉ុន្តែការប៉ុនប៉ងនេះត្រូវបរាជ័យ ដោយសារសមត្ថកិច្ចបានរកឃើញនិងបង្ក្រាបទាន់ពេលវេលាជាបន្តបន្ទាប់ដូចជា :

-ទីតាំងផលិតសារធាតុគីមីផ្សំដ៏សំខាន់ក្នុងការផលិតគ្រឿងញៀនសំយោគ**ATS** ត្រូវបានរកឃើញ និង បង្ក្រាបនៅថ្ងៃទី០១ខែមេសាឆ្នាំ២០០៧ នៅក្នុងឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងខណៈដែលទីតាំងនោះកំពុងរៀបចំដំណើការផលិត និងកន្លែងស្តុកសារធាតុគីមីផ្សំមួយកន្លែងទៀតស្ថិតនៅក្នុងសង្កាត់ទួល ស្វាយព្រៃទី២ខណ្ឌចំការមន ។

-ទីតាំងទី២ ត្រូវបានរកឃើញនៅថ្ងៃទី០១ខែសីហាឆ្នាំ២០០៧ នៅក្នុងសង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ ក្រុងភ្នំពេញ ដោយបានធ្វើការដកហូតនូវម៉ាស៊ីនគៀបគ្រាប់ថ្នាំស្វ័យប្រវត្តិ១គ្រឿងនិងវត្ថុតាងផ្សេងៗ

ទៀតជាច្រើន ។

**-ការចាប់ដុះដំណាំកញ្ឆា :**

មកទល់ពេលនេះ យើងទទួលបានជោគជ័យក្នុងការបំផ្លាញដំណាំកញ្ឆានិងទប់ស្កាត់បាននូវសកម្ម-ភាពជួញដូរ និង ការលបលួចដាំដុះកញ្ឆារបស់ជនទុច្ចរិត ។

**-ការផលិតប្រេងម្រះព្រៅ :**

ទន្ទឹមនឹងដំណាំកញ្ឆាត្រូវបានកាត់បន្ថយដល់កំរិតអតិបរិមា បែរជាលេចចេញនូវការផលិតប្រេងម្រះព្រៅភ្នំ ដោយសារនៅក្នុងប្រេងម្រះព្រៅមានផ្ទុកនូវសារធាតុសាហ្វ្រុលខ្ពស់ ។ សកម្មភាពនេះបានកើតមាននៅតំបន់ព្រៃភ្នំនៃព្រំប្រទល់ខេត្តកោះកុង បាត់ដំបង ពោធិសាត់។ អគ្គលេខាធិការដ្ឋាន អជបគញ បានសហការជាមួយUNODCក្នុងការរៀបចំសិក្ខាសាលាស្តីពីការផលិត ការធ្វើពាណិជ្ជកម្មប្រេងរុក្ខជាតិ ដែលមានសារធាតុសាហ្វ្រុលខ្ពស់ និងធ្វើការប្រជុំជាមួយក្រសួងពាក់ព័ន្ធជាបន្ទាន់ដើម្បីពិភាក្សាបញ្ហានេះ ហើយដោយមានការណែនាំពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ប្រធាន អជបគញ ក្រសួងសុខាភិបាលបានចេញប្រកាសស្តីពីការបញ្ចូលប្រេងម្រះព្រៅភ្នំទៅក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២.ការចរាចរ ចែកចាយ :**

ជារួម ច្រកនៃបណ្តាខេត្តតាមបណ្តោយព្រំដែនថៃ ឡាវ និងផ្លូវអាកាស នៅតែជាច្រកគោលដៅដែលឧក្រិដ្ឋជនគ្រឿងញៀនក្នុងតំបន់និងអន្តរជាតិធ្វើសកម្មភាពយ៉ាងសកម្មក្នុងការដឹកជញ្ជូនគ្រឿងញៀន ។

**ហេរ៉ូអ៊ីន**និងគ្រឿងញៀនសំយោគ**ATS** ត្រូវឧក្រិដ្ឋជនគ្រឿងញៀននាំពីតំបន់ត្រីកោណមាសចូលតាមច្រកផ្លូវទឹកនិងផ្លូវគោកនៃបណ្តាខេត្តភាគខាងជើងនិងឥសានប្រទេស(ពិសេសខេត្តស្ទឹងត្រែង) ។

**ហេរ៉ូអ៊ីន** ភាគច្រើនធ្វើសកម្មភាពដោយក្រុមឧក្រិដ្ឋជនបរទេសប្រើប្រាស់លិខិតឆ្លងដែនតៃវ៉ាន់ ឬចិនដីគោក ។ ក្រុមនេះ នាំហេរ៉ូអ៊ីនតាមផ្លូវអាកាសចេញទៅក្រៅប្រទេស ។

**ដោយឡែក មេតំហ្វេតាមីនICE** ភាគច្រើនធ្វើសកម្មភាពនាំចេញទៅក្រៅប្រទេសតាមផ្លូវអាកាសដោយពួកឈ្មួញគ្រឿងញៀនបរទេសដែលប្រើប្រាស់លិខិតឆ្លង ដែនប្រទេសម៉ាឡេស៊ី ។

**ចំណែក ប្រេងម្រះព្រៅ** ពួកឈ្មួញបានបង្វែរទិសពីការដឹកជញ្ជូនតាមផ្លូវជាតិលេខ៥មកធ្វើការដឹកជញ្ជូនពីខេត្តកោះកុងឆ្លងកាត់ខេត្តកំពតដើម្បីនាំទៅប្រទេសវៀតណាម ។

**៣.ការប្រើបំពានគ្រឿងញៀន :**

**ការប្រើបំពានគ្រឿងញៀន** ច្រើនកើតមាននៅទីក្រុងភ្នំពេញនិងបណ្តាខេត្តជាប់ព្រំដែនថៃ ព្រោះតំបន់នោះប្រមូលផ្តុំដោយក្រុមជនងាយទទួលរងគ្រោះ និងក្រុមជនដែលធ្វើចំណាកស្រុកឆ្លងដែនទៅប្រកបរបរដោយពលកម្ម ។ **ការប្រើបំពានគ្រឿងញៀនបច្ចុប្បន្ន** កាន់តែបង្ហាញពីភាពគ្រោះថ្នាក់ដោយសារភាគច្រើនគេប្រើវិធីចាក់ដោយប្រើប្រាស់ម្ជុល/ស៊ីរ៉ាំងមិនស្អាតរួមគ្នា ។ អគ្គលេខាធិការដ្ឋានបាននិងកំពុងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលជាដៃគូ ក្នុងការចុះសិក្សាស្រាវជ្រាវរក

អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមអ្នកញៀនគ្រឿងញៀននៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប និងភ្នំពេញ ។

## II / សកម្មភាពការងាររបស់ឯកឧត្តមប្រធាន អជបគញ :

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់នៅក្នុង :

-កិច្ចប្រជុំលើកទី៣នៃបណ្តាខេត្តជាប់ព្រំដែនវៀតណាម និង ទស្សនកិច្ចផ្លូវការ នៅប្រទេសឡាវ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ រក្សាសន្តិសុខនិងបញ្ហាគ្រឿងញៀននៃប្រទេសទាំងបី ។

-សិក្ខាសាលាគំរោង **F34** របស់ **UNODC** អនុតំបន់ ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ។

-សិក្ខាសាលាចាប់ផ្តើមអនុវត្តគំរោង **H83** ស្តីពីការអភិវឌ្ឍន៍លើ សេវាប្រឹក្សា ព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

-កិច្ចប្រជុំរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុងឆ្នាំ២០០៧ ។ នៅក្នុងកិច្ចប្រជុំឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានសង្កត់ធ្ងន់លើការងារអនុវត្តច្បាប់, ការងារអប់រំ ផ្សព្វផ្សាយ, ការព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀន, នីតិកម្ម-ផែនការ, កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើស គ្រឿងញៀន ។

-មីទ្ទិញអបអរសាទរទិវាអន្តរជាតិប្រឆាំងការចរាចរជួញដូរ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ នៅខេត្តបាត់ដំបង ។

-ពិធីផ្សព្វផ្សាយនិងផ្តល់ជូន នូវសៀវភៅកំរងអត្ថបទយល់ដឹងពីគ្រឿងញៀនដែលមួយប្រភេទសំរាប់ផ្តល់ជូនមន្ត្រីអនុវត្តច្បាប់និងតុលាការ មួយប្រភេទសំរាប់គ្រូបង្រៀននិងមាតាបិតានិងមួយប្រភេទទៀត សំរាប់ផ្នែកបំរើសេវាសុខភាពនិងសង្គម (សរុបមានចំនួន **១១.000** ក្បាល) ។

-ពិធីដុតបំផ្លាញសារធាតុគីមីផ្សំនៅខេត្តកំពង់ស្ពឺនិងភ្នំពេញ (**ករណី KP 147**) ។

-សិក្ខាសាលាតំបន់ ស្តីពីការឈានឆ្ពោះទៅរកប្រសិទ្ធិភាពនៃការព្យាបាលអ្នកញៀននៅអាស៊ី ។

**ចំពោះការងារសរសើរលើកទឹកចិត្ត** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ បាន :

-ចេញប្រកាសស្តីពីការបង្កើតប័ណ្ណសរសើររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងលិខិតសរសើររបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-ប្រគល់សញ្ញាប័ត្រដល់សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលការព្យាបាល ស្តារនីតិសម្បទាអ្នកញៀន ។

-បំពាក់គ្រឿងឥស្សរិយយស និងជូនប័ណ្ណសរសើរដល់មន្ត្រីស្ថានទូតបរទេស អង្គការជាតិ អន្តរ-ជាតិ និងអង្គការក្រៅរដ្ឋាភិបាលដែលបានសហការការងារល្អជាមួយអាជ្ញាធរជាតិ ។

**ដោយឡែក** ឯកឧត្តម **តេង សាវង្ស** អនុប្រធានអចិន្ត្រៃយ៍អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានទទួល ការចាត់តាំងពីឯកឧត្តមប្រធាន អជបគញ ឱ្យដឹកនាំការងារមួយចំនួនដូចខាងក្រោម :

-ដឹកនាំគណៈកម្មការស្រាវជ្រាវត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដែលរឹបអូសនៅខេត្តកំពង់

ស្ដី និងនៅទីក្រុងភ្នំពេញ ។ ករណីនេះបានឈានដល់ការបំផ្លាញចោលប្រកបដោយជោគជ័យ ។

–ដឹកនាំប្រតិភូទៅចូលរួមក្នុងកិច្ចប្រជុំ **ថ្នាក់មន្ត្រីជាន់ខ្ពស់** និង **ថ្នាក់រដ្ឋមន្ត្រី** នៃបណ្ដាប្រទេសជាសមាជិកហត្ថលេខីលើអនុស្សារណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣ (MOU) ស្ដីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន។ក្នុងឱកាសនោះឯកឧត្តមបានជួបជាមួយលោក**Antonio Maria Costa** អគ្គលេខាធិការរងអង្គការសហប្រជាជាតិនិងជានាយកប្រតិបត្តិប្រចាំទីក្រុងវីយែន ភាគីចិន ថៃ វៀតណាម ហើយបាន :

- ស្នើសុំ**UNODC** ដើម្បីបង្កើតការិយាល័យរបស់ខ្លួនជាផ្លូវការ នៅកម្ពុជា ។
- ស្នើសុំភាគីចិននូវឱសថសំរាប់ព្យាបាលអ្នកញៀន ការជួយបណ្ដុះបណ្ដាលធនធានមនុស្សសម្ភារៈបច្ចេកទេសសំរាប់មជ្ឈមណ្ឌលព្យាបាលនិងស្នើសុំឱ្យមានអនុស្សារណៈ នៃការយោគយល់គ្នាទ្វេភាគីស្ដីពីកិច្ច សហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។
- ស្នើសុំវៀតណាមផ្ដល់លទ្ធភាពឱ្យកម្ពុជា បានធ្វើទស្សនកិច្ចសិក្សាលើការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀន ។
- ស្នើសុំភាគីថៃបន្តជួយបណ្ដុះបណ្ដាលជំនាញរយៈពេលខ្លី អំពីរបៀបប្រើប្រាស់ម៉ាស៊ីនវិភាគគ្រឿងញៀនប្រភេទ GC-MS ។

–ដឹកនាំក្រុមការងារច្បាប់ដើម្បីការពារសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងពិធីសារឆ្នាំ១៩៧២ ដែលបានធ្វើវិសោធនកម្មអនុសញ្ញាទោលស្ដីពីគ្រឿងញៀនឆ្នាំ ១៩៦១នៅរដ្ឋសភា និង ព្រឹទ្ធសភា ។

## III / <u>លទ្ធផលនៃកិច្ចប្រតិបត្តិការ</u> :

### ***១. ការងារអនុវត្តច្បាប់***

### ***ក. លទ្ធផលបង្ក្រាប :***

**–បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **១២៦** ករណី / ចាប់ខ្លួនជនល្មើស **២២៩** នាក់ ។

**–វត្ថុតាងរឹបអូស** មេតំហ្វេតាមីនគ្រាប់ **២៨០.៦៣៨** គ្រាប់, មេតំហ្វេតាមីនICE **៦.៦៦១,០៨** ក្រាម, ហេរ៉ូអ៊ីន **១០.១៩០,៥** ក្រាម, អ៊ិកស្តាស៊ី **៣០០** គ្រាប់, ម៉េប្យាំហ្វេតាមីន **៦០០** ក្រាម, ថ្នាំវីយ៉ាក្រា **៤៤**គ្រាប់, កញ្ឆាក្រៀម**១០,០៥** គ.ក្រ, កញ្ឆាគ្រីប**២០៣**គីឡូ, សារធាតុគីមីផ្សំគ្រឿងញៀន **៥.៧៧០,២៥** គីឡូក្រាម, ប្រេងម្រះព្រៅ**១.២៦០**លីត្រ, បំផ្លាញដំណាំកញ្ឆា**១.០៧៥**ម[២] ,ពុម្ពដែក**៦**, ដង្កៀសង្កត់គ្រាប់ថ្នាំ**២**, ម៉ាស៊ីនសម្ងួត**១**, ម៉ាស៊ីនគៀបគ្រាប់ថ្នាំស្វ័យប្រវត្តិ**១**គ្រឿង និងវត្ថុតាងពាក់ព័ន្ធជាច្រើនទៀត ។

**ដោយឡែក :**

–**ក្រុងភ្នំពេញ និង ខេត្តបន្ទាយមានជ័យ** បានធ្វើការបំផ្លាញថ្នាំញៀនប្រភេទគ្រាប់សរុបចំនួន

១៤៣.៣២៧គ្រាប់, ប្រភេទម្សៅចំនួន៧០,៥៤៩គ.ក្រ, ប្រភេទទឹកចំនួន១.៩៥១កូនដប ( ក្នុងឱកាសអបអរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃ២៦/៦/២០០៧) ។

**–ខេត្តពោធិសាត់**បានចុះទៅបំផ្លាញទីតាំងលបលួចផលិតប្រេងម្រះព្រៅភ្នំ នៅក្នុងភូមិសាស្ត្រឃុំអន្លង់រាបស្រុកវាលវែងចំនួន៧កន្លែង សរុបមាន ឆ្នាំចំហុយ៧, កាំបិតឈូសគល់ដើមម្រះព្រៅភ្នំ៥, ធុងស្ល ប្រេង៥ និងដុតកន្លែងស្នាក់នៅរបស់កម្មករចំនួន២៦ជម្រក ។

***ខ. ការងារមន្ទីរពិសោធន៍គ្រឿងញៀន :***

៩ខែនេះ មន្ទីរពិសោធន៍គ្រឿងញៀន អជបកញ បានទទួលធ្វើកោសល្យវិច័យលើសំណាកវត្ថុតាង សរុបបានចំនួន **១៦១** សំណាក ។ លទ្ធផលគឺ **សំណាកអវិជ្ជមាន**ចំនួន **៦** សំណាក ,**សំណាកវិជ្ជមាន**ចំនួន **១៥៥**សំណាកគឺ **មេតំហ្វេតាមីនICE**២៨សំណាក, **មេតំហ្វេតាមីនគ្រាប់** ១០៤សំណាក, **ហេរ៉ូអ៊ីន**១៤សំណាក, **អ៊ិចស្តាស៊ី** ២សំណាក, **កូកាអ៊ីន** ២សំណាក, **សារធាតុគីមីផ្សំ** ៤សំណាក, សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ **១សំណាក** ។ ជាមួយនោះ មន្ទីរពិសោធន៍គ្រឿងញៀន នៃអគ្គលេខាធិការដ្ឋានក៏បានទទួលនូវ :

–ម៉ាស៊ីនពិសោធន៍គ្រឿងញៀនប្រភេទ **GC-MS** ពីប្រទេសបារាំង ។

–កិច្ចសហការជាមួយស្ថាប័ន**DEA** ក្នុងការជួសជុលឱ្យដំណើរការឡើងវិញនូវម៉ាស៊ីនពិសោធន៍គ្រឿងញៀនអាមេរិកផ្តល់ឱ្យកាលពីឆ្នាំ១៩៩៩ ។

***គ. ការងារបណ្តុះបណ្តាល និង ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់***

អគ្គលេខាធិការដ្ឋាន អជបកញ បានយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងការអនុវត្តន៍គំរោងនានា ក្នុងការបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ទទួលបានលទ្ធផលដូចតទៅ :

–តាមរយៈគំរោង**F34** របស់**UNODC**អនុតំបន់ បានរៀបចំសិក្ខាសាលា ក្រោមប្រធានបទស្តីពីការផលិត ការធ្វើពាណិជ្ជកម្មប្រេងរុក្ខជាតិដែលមានសារធាតុសាហ្វ្រុលខ្ពស់ ។

–តាមរយៈគំរោង**D91** ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គរបស់**UNODC** ដែលទើបបញ្ចប់អាណត្តិរបស់ខ្លួនកាលពីខែមីនាកន្លងទៅបានបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (**BLO** ) ចំនួន**៧**កន្លែង :

- តាមព្រំដែនថៃ ២កន្លែង : នៅ **ចាំយាម** (កោះកុង) និង **ប៉ោយប៉ែត** (បន្ទាយមានជ័យ)
- តាមព្រំដែនឡាវ ២កន្លែង : **នៅ ដុងក្រឡ** និង **ឈើទាលធំ** (ស្ទឹងត្រែង)
- តាមព្រំដែនវៀតណាម ៣កន្លែង : **បាវិត** (ស្វាយរៀង) និង **ជ្រៃធំ**, **ក្អមសំណ** (កណ្តាល)

–តាមរយៈគំរោង**AD/RAS/I61** (ដែលត្រូវបន្តអាណត្តិពីគំរោង**D91**) នឹងបង្កើតការិយាល័យ**BLO** ចំនួន**៥**កន្លែងទៀតនៅ ក្នុងក្រុងប៉ៃលិន**១**កន្លែង, ខេត្តបាត់ដំបង**១**កន្លែង, ខេត្តឧត្តរមានជ័យ**២**កន្លែង និង (នៅខេត្តកំពង់ចាម ឬ តាកែវ**១**កន្លែង) ។

-គំរោង **KHM/J11** របស់**UNODC** ស្តីពីការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ ។

-គំរោងទ្វេភាគីកម្ពុជា-**JICA**ជប៉ុន ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ដែលមានទិសដៅពង្រឹងលើការងារអនុវត្តច្បាប់, ការងារមន្ទីរពិសោធន៍ និង ការងារអប់រំបង្ការ ។

-គំរោង **JICA**តំបន់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-គំរោង **H84** របស់ **UNODC** ស្តីពីការអភិវឌ្ឍន៍កម្មវិធីកែប្រែដំណាំជំនួសដំណាំគ្រឿងញៀន ។

-តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (**ONCB**) យើងទទួលបាននូវសម្ភារៈការិយាល័យ **BLO** ចំនួន៤កន្លែងនៅច្រក **ព្រំ** (ប៉ៃលិន), **ច្រកដូង** (បាត់ដំបង), **ច្រកជាំ** និង **ច្រកអូរស្មាច់** (ឧត្តរមានជ័យ) និងទទួលបាននូវការបណ្តុះបណ្តាលលើការងារអនុវត្តច្បាប់, ការងារព្យាបាលសំរាប់មន្ត្រីកម្ពុជាដែលនៅតាមបណ្តាខេត្តជាប់ព្រំដែន ។

## ២. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

### ក- ការងារផ្សព្វផ្សាយអប់រំ :

៩ខែកន្លងមកនេះ សកម្មភាពផ្សព្វផ្សាយអប់រំសំដៅធ្វើឱ្យមានការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀនកាន់តែត្រូវបានពង្រីកនឹងពង្រឹង ។ ក្រៅពីបានបញ្ជ្រៀបការយល់ដឹងពីគ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាដោយក្រសួងអប់រំយុវជននិងកីឡា អគ្គលេខាធិការដ្ឋានបានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ, អង្គការអន្តរជាតិ, អង្គការក្រៅរដ្ឋាភិបាលជាដៃគូអនុវត្តនូវ :

-កម្មវិធីអប់រំផ្សព្វផ្សាយដល់មន្ត្រីរាជការ លោកគ្រូ-អ្នកគ្រូ កងកម្លាំងប្រដាប់អាវុធ សិស្សា-នុសិស្សប្រជាពលរដ្ឋនៅតាមបណ្តាខេត្ត-ក្រុងនានា សំដៅលើកកំពស់ការយល់ដឹងផលប៉ះពាល់នៃគ្រឿងញៀនទៅលើសង្គមជាតិ និង កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលដល់អង្គការដៃគូ ។

-សហការក្នុងការអនុវត្តន៍កម្មវិធីបណ្តាញព័ត៌មាននិងសកម្មភាពគ្រប់គ្រងការប្រើប្រាស់គ្រឿងញៀន ជាមួយអង្គការកម្មវិធី**IOGT-RIANDAC** រួមជាមួយមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC), សមា-គមយុវជនខ្មែរ (**KYA**), អង្គការពន្លឺកុមារកម្ពុជា (**PKKO**) ។ ជាមួយនោះក៏មានអង្គការសង្គមស៊ីវិលជាង ២០ផ្សេង ទៀតបាននិងកំពុងសហការល្អជាមួយអគ្គលេខាធិការដ្ឋាន លើការងារអប់រំផ្សព្វផ្សាយនេះ ។

-ការផលិតសម្ភារៈនិងឯកសារផ្សព្វផ្សាយរួមមានខិតប័ណ្ណ, Poster, អាវយឺត, មួក, បដាកាន់ដៃ, បដាចងតាមផ្លូវ សំរាប់ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន២៦/៦/២០០៧ ដែលគាំទ្រថវិកាដោយអង្គការ**UNODC JICA KHANA** និង **WHO** ។

-ការផលិតកំរងអត្ថបទយល់ដឹងពីគ្រឿងញៀនចំនួន៥ប្រភេទ សំរាប់ផ្តល់ជូនមន្ត្រីអនុវត្តច្បាប់និងតុលាការ, គ្រូបង្រៀននិងមាតាបិតា, ផ្នែកសេវាសុខភាពនិងសង្គម ។

-កម្មវិធីស្រាយបំភ្លឺពីបញ្ហាគ្រឿងញៀនតាមវិទ្យុ-ទូរទស្សន៍និងវេទិកាផ្សេងៗសំរាប់មិត្តអ្នកស្តាប់ ។

### ខ- ការកាត់បន្ថយគ្រោះថ្នាក់ និង ការបង្ការការឆ្លងមេរោគអេដស៍ដែលបណ្តាលមកពីការប្រើចំពាន គ្រឿងញៀន :

ដើម្បីកាត់បន្ថយគ្រោះថ្នាក់ និង បង្ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អជបគញ បាន :

–សហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ បង្កើតឡើងនូវក្រុមការងារគ្រឿងញៀន / អេដស៍ (**D/HA** ) ដែលមានលេខាធិការដ្ឋាននៅក្នុងអគ្គលេខាធិការដ្ឋាន អជបគញ ។

–សហការជាមួយអង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជម្ងឺអេដស៍ (KHANA ) ដើម្បីរៀបចំឱ្យមាន :

• ការប្រជុំប្រចាំត្រីមាសរវាងអគ្គលេខាធិការដ្ឋានជាមួយនឹងបណ្តាញអង្គការក្រៅរដ្ឋាភិបាល ដែល អនុវត្តគំរោងឆ្លើយតបការប្រើបំពានគ្រឿងញៀន ។

• រៀបចំវេទិកាតុមូលពិភាក្សាអំពីការប្រើបំពានគ្រឿងញៀនផលប៉ះពាល់និងការចម្លងមេរោគអេដស៍/ជម្ងឺអេដស៍ ។

• រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយក្នុងពិធី បុណ្យអុំទូកអកអំបុកនិងសំពះព្រះខែនៅទីក្រុងភ្នំពេញ ។

• រៀបចំសិក្ខាសាលាស្តីពីទំនាក់ទំនងគ្រឿងញៀននិងមេរោគអេដស៍/ជម្ងឺអេដស៍ សំរាប់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនក្រុងភ្នំពេញ បាត់ដំបង កំពង់ស្ពឺ កំពង់ឆ្នាំង ព្រៃវែង សៀមរាប និង ក្រុងព្រះសីហនុ ។

• បោះពុម្ពបន្ថែមសៀវភៅច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននិងអនុសញ្ញាគ្រឿងញៀនអន្តរជាតិ ។

–ចូលរួមពិនិត្យលើសេចក្តីព្រាងគោលការណ៍ណែនាំការអនុវត្តន៍កម្មវិធីម្ជុល/សុីរាំងនៅកម្ពុជា ។

–ចូលរួមពិភាក្សាលើការកសាងគោលនយោបាយគ្រឿងស្រវឹងនៅកម្ពុជា ។

–សហការរៀបចំគំរោងស្នើសុំថវិកាទៅមូលនិធិសកលជុំទី៧ សំរាប់ដំណើរការគំរោងនានាពាក់ព័ន្ធនឹងការងារបង្ការទប់ស្កាត់ការឆ្លងរីករាលដាលមេរោគអេដស៍ដែលបណ្តាលពីការប្រើគ្រឿងញៀន។

**ឥ - ការងារព្យាបាល/ស្តារនីតិសម្បទាអ្នកញៀន**

**- អំពីមជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទា**

បច្ចុប្បន្ននេះ យើងមានមជ្ឈមណ្ឌលព្យាបាលរបស់រដ្ឋចំនួន១០កន្លែង ដែលកំពុងទទួលព្យាបាលអ្នកញៀន ប្រមាណ ៧២៧ នាក់ ។ មជ្ឈមណ្ឌលទាំងនោះមាននៅ :

–ខេត្តបាត់ដំបង **ពីរកន្លែង** ជារបស់កងរាជអាវុធខេត្ត និង នគរបាលខេត្ត ។

–ខេត្តបន្ទាយមានជ័យ **ពីរកន្លែង** ជារបស់កងរាជអាវុធខេត្ត និង ក្រសួងសង្គមកិច្ច ។

–ក្រុងភ្នំពេញ **ពីរកន្លែង** ជារបស់ក្រសួងសង្គមកិច្ច និង សាលាក្រុង

–ខេត្តសៀមរាប **មួយកន្លែង** ជារបស់នគរបាលខេត្ត

–ខេត្តកោះកុង **មួយកន្លែង** ជារបស់ក្រសួងសង្គមកិច្ច

–ខេត្តកំពង់ចាម **មួយកន្លែង** ជារបស់កងរាជអាវុធហត្ថខេត្ត

–ក្រុងព្រះសីហនុ **មួយកន្លែង** ជារបស់កងរាជអាវុធហត្ថខេត្ត

**- អំពីការងារបណ្តុះបណ្តាលធនធានមនុស្ស**

ការងារនេះ អគ្គលេខាធិការដ្ឋាន អជបគញ បាននិងកំពុងសហការជាមួយ**UNODC** ក្នុងការអនុវត្តន៍គំរោងមួយចំនួនដូចខាងក្រោម :

-គំរោង **H83** កន្លងមកបានបើកសិក្ខាសាលាជាបន្តបន្ទាប់នៅក្រុងព្រះសីហនុ, បាត់ដំបង, បន្ទាយមានជ័យ និង សៀមរាប ក្រោមប្រធានបទស្តីពី :

- ការផ្តល់ប្រឹក្សាចំពោះគ្រួសារដែលទទួលរងឥទ្ធិពលគ្រឿងញៀន ។
- ការអង្កេតបឋមលើឥរិយាបថអ្នកប្រើគ្រឿងញៀន និងដៃគូរួមភេទរបស់គេ ។
- ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ។ មួយផ្នែកនៃគំរោងនេះបានគាំទ្រ លើការអនុវត្តន៍គោលការណ៍ណែនាំស្តីពីប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀនក្នុងការធ្វើបច្ចុប្បន្ន ភាពអ្នកប្រើគ្រឿងញៀននៅតាមខេត្ត-ក្រុងអាទិភាពចំនួន១២ ដើម្បីជ្រើសរើសគ្រូបង្គោល និងធ្វើការវាយ តម្លៃជ្រើសរើសឃុំ **ស-ប្រផេះ-ខ្មៅ** ។

-គំរោងស្តីពីការពង្រឹងសមត្ថភាពការព្យាបាល/ការបង្ការការឆ្លងមេរោគអេដស៍ ក្នុងចំណោមអ្នកប្រើគ្រឿងញៀននិងអ្នកនៅក្នុងមន្ទីរឃុំឃាំងដែលកន្លងមកបានបើកសិក្ខាសាលានៅក្នុងប្រទេសពីរវគ្គ។

-គំរោង**I13** ស្តីពីការធ្វើឱ្យប្រសើរនូវសេវាព្យាបាលយុវជនដែលប្រើថ្នាំញៀន**ATS**នៅកម្ពុជា គឺយើងបានបញ្ជូនមន្ត្រីទៅចូលរួមក្នុងសិក្ខាសាលានៅក្រៅប្រទេស ។

៣-**ក្រៅពីនោះ**

-តាមរយៈជំនាញការអាល្លឺម៉ង់ប្រចាំអគ្គលេខាធិការដ្ឋាន អង្គការ **Day Top International** របស់អាមេរិកបានបើកសិក្ខាសាលា ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀនកន្លងមកបានចំនួន៣វគ្គ ។

-ប្រទេសអូស្ត្រាលី នឹងជួយលើកម្មវិធីបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀននិងវិធីសាស្ត្រព្យា-បាលអ្នកញៀនតាមរយៈការប្រើប្រាស់សារធាតុមេតាដូន ។

**ឥ- ការងារមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន :**

តាមរយៈការគាំទ្រពីអង្គការសុខភាពគ្រួសារអន្តរជាតិ (**FHI**) អង្គការសុខភាពពិភពលោក (**WH**) និងគំរោង**F97**ស្តីពីការធ្វើឱ្យប្រសើរនូវការប្រមូលទិន្នន័យ**ATS**និងប្រព័ន្ធព័ត៌មានគ្រឿងញៀន អគ្គលេខា-ធិការដ្ឋានបានធ្វើការអភិវឌ្ឍន៍លើប្រព័ន្ធប្រមូលទិន្នន័យការប្រើបំពានគ្រឿងញៀនដោយបានរៀបចំ :

-ក្រុមមន្ត្រីទំនាក់ទំនង (Focal Point) ដែលបំរើការងារនៅតាមមជ្ឈមណ្ឌលព្យាបាលរបស់រដ្ឋ ។

-ចងក្រងទិន្នន័យព្យាបាលឆ្នាំ២00៦ ។

-បង្កើតទម្រង់បែបបទចុះទិន្នន័យអ្នកញៀនដែលមកទទួលការព្យាបាលនៅតាមមជ្ឈមណ្ឌល ។

-រៀបចំបោះពុម្ពកូនសៀវភៅសំរាប់ណែនាំដល់អ្នកប្រើប្រាស់ទម្រង់បែបបទនេះ ។

-រៀបចំបណ្តុះបណ្តាលពីការងារទិន្នន័យព្យាបាលនិងស្ថានីតិសម្បទាអ្នកញៀន ។

-បណ្តុះបណ្តាលមន្ត្រីក្រុមប្រមូលទិន្នន័យ ព័ត៌មានគ្រឿងញៀនស្តីពីអត្តសញ្ញាណគ្រឿងញៀនតាមឯកសារ**CBT** ។

–ប្រជុំក្រុមការងារបច្ចេកទេសគ្រឿងញៀន/អេស៍ (**DHA**) ដើម្បីកំណត់បែងចែកភារកិច្ចរបស់អង្គការជាតិ អន្តរជាតិ និងអង្គភាពពាក់ព័ន្ធក្នុងការបញ្ជូនទិន្នន័យព័ត៌មានគ្រឿងញៀនមកអគ្គលេខាធិការដ្ឋាន ។

–តាមដានត្រួតពិនិត្យការអនុវត្តន៍កម្មវិធីម្ទុល/ស៊ីរ៉ាំងរបស់អង្គការមិត្តសំឡាញ់និងអង្គការកសាង ។

–សហការជាមួយវិទ្យាស្ថាន**Burnet**,មជ្ឈមណ្ឌលប្រយុទ្ធនឹងជម្ងឺអេដស៍សើស្បែកនិងកាមរោគ, អង្គការមិត្តសំឡាញ់,អង្គការកសាងនិង**WHO** ដើម្បីរៀបចំគំរោងធ្វើអង្កេតអ្នកប្រើប្រាស់គ្រឿងញៀន**ATS** ។

### ៣. ការងារនីតិកម្ម និង ផែនការ

–រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ លេខ១៣អនក្រ/បក ចុះថ្ងៃទី២២ខែកុម្ភៈឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អជបគញ ។

យោងតាមការចាំបាច់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន :

–កសាងផែនការសកម្មភាពជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៨ ។

និងបានបង្កើតបន្ថែមនូវបណ្តាបទដ្ឋានគតិយុត្តិ រួមមាន :

–សេចក្តីណែនាំ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន រវាងប្រទេសកម្ពុជា–វៀតណាម–ឡាវ ។

–សេចក្តីសំរេច ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀនដែលរឹបអូសនៅខេត្តកំពង់ស្ពឺនិងក្រុងភ្នំពេញ ។

–សារាចរណែនាំ ស្តីពីការឆែកឆេរ ការដកហូត ការវេចខ្ចប់ ការរក្សាទុកវត្ថុតាងនិងការដកយកសំណាកបញ្ជូនទៅធ្វើកោសល្យវិច័យក្នុងបទល្មើសគ្រឿងញៀន ។

–ប្រកាសស្តីពីការបញ្ចូលប្រេងម្រះព្រៅភ្នំទៅក្នុងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

–គោលការណ៍ណែនាំ ស្តីពីការអនុវត្តន៍កម្មវិធីម្ទុល/ស៊ីរ៉ាំង នៅកម្ពុជា ។

–សេចក្តីសំរេចស្តីពីការបង្កើតក្រុមការងារ បង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀននៅតាមសាលារៀន ។

–សេចក្តីសំរេចស្តីពីការបង្កើតក្រុមការងារ អន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ (កែសំរួលសមាសភាពថ្មីឡើងវិញ) ។

–ក្រុមការងារ អនុវត្តគំរោងH83ស្តីពីការអភិវឌ្ឍន៍ជាមូលដ្ឋានតាមសហគមន៍លើសេវាប្រឹក្សាព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

–សេចក្តីសំរេចស្តីពីការបង្កើតក្រុមការងារគ្រឿងញៀន/អេដស៍ (DHA. Drugs – Hiv / Aids) ។

–សេចក្តីសំរេចស្តីពីការបង្កើតក្រុមការងារបង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ។

**ឆ– កិច្ចសហប្រតិបត្តិការអន្តរជាតិ :**

អគ្គលេខាធិការដ្ឋាន អជបគញ បានទៅចូលរួមនៅក្នុងកិច្ចប្រជុំថ្នាក់តំបន់និងអនុតំបន់ រួមមាន :

–កិច្ចប្រជុំលើកទី២ របស់ក្រុមសហប្រតិបត្តិការអាស៊ីសំរាប់ត្រួតពិនិត្យសារធាតុគីមីផ្សំក្នុងស្រុក ។

–សន្និសីទអន្តរជាតិលើកទី៣ ស្តីពីសារធាតុគីមីផ្សំសំរាប់ផលិតគ្រឿងញៀន **ATS** ។

–សន្និសីទអន្តរជាតិលើកទី១២ស្តីពីការអនុវត្តច្បាប់គ្រឿងញៀននៅអាស៊ី–ប៉ាស៊ីហ្វិក (ADCE 12 ) ។

–កិច្ចប្រជុំ**ADLOMIKO** លើកទី១៧ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀនអន្តរជាតិ ។

–កិច្ចប្រជុំប្រចាំឆ្នាំរបស់មន្ត្រីទំនាក់ទំនងគំរោង **H15** ។

–កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ និង ថ្នាក់រដ្ឋមន្ត្រីនៃបណ្តាប្រទេសសមាជិកហត្ថលេខីលើអនុស្សារណៈនៃការយោគយល់គ្នា (**MOU** ) ឆ្នាំ១៩៩៣ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

–កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់លើកទី២៨ ស្តីពីកិច្ចការគ្រឿងញៀន (**ASOD** ) ។

–កិច្ចប្រជុំក្រុមការងាររបស់អាស៊ាន+ចិន ប្រឆាំងគ្រឿងញៀនដែលមានគ្រោះថ្នាក់ (**ACCORD** ) ។

–កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (**SOMTC+3** ) ។

–កិច្ចប្រជុំក្រុមការងារយន្តការ **MOU** ។

–កិច្ចប្រជុំក្រុមប្រទេសផ្តល់ជំនួយ (**Mni-dublin Group** ) បានសំរេចគាំទ្រកម្ពុជាដូចតទៅ :

**ផ្នែកកាត់បន្ថយការផ្គត់ផ្គង់** គាំទ្រដោយអង្គការ **UNODC**

**ផ្នែកអប់រំបង្ការ**គាំទ្រដោយ ជប៉ុន អូស្ត្រាលី អាមេរិក អង់គ្លេស អាល្លឺម៉ង់ និង អង្គការ **UNODC**

**ផ្នែកអនុវត្តច្បាប់**គាំទ្រដោយ ជប៉ុន អូស្ត្រាលី បារាំង កាណាដា អាមេរិក និង អង្គការ **UNODC**

- **<u>ក្រុមអ្នកជំនាញការ ប្រចាំអគ្គលេខាធិការដ្ឋាន អជបគញ</u>** រួមមាន :

១–ជំនាញការអាល្លឺម៉ង់ ១រូប ទទួលបន្ទុកការងារអប់រំផ្សព្វផ្សាយ និង ការងារព្យាបាល ។

២–ជំនាញការ**JICA**ជប៉ុន១រូប ទទួលបន្ទុកការងារអនុវត្តច្បាប់, មន្ទីរពិសោធន៍គ្រឿងញៀន និង ការងារអប់រំបង្ការ ។

## IV / <u>ការសន្និដ្ឋាន និង វាយតម្លៃ :</u>

បើធ្វើការពិនិត្យនិងវាយតម្លៃអំពីលទ្ធផលការងារខាងលើ ជាមួយនឹងផែនការសកម្មភាពដែលមានចែងក្នុងផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២00៧ឃើញថា សកម្មភាពភាគច្រើនត្រូវបាននិងកំពុងអនុវត្ត ។ ជាបន្តបន្ទាប់យើងបានទទួលនូវការគាំទ្រនិងវាយតម្លៃខ្ពស់ពីសំណាក់បណ្តាប្រទេសម្ចាស់ជំនួយនិងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិនានា ពីលទ្ធផលនិងកិច្ចខិតខំប្រឹងប្រែងរបស់ រាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ពិសេស ដូចករណីនៅខេត្តកំពង់ស្ពឺជាដើម ។

ផ្តើមចេញពីការអនុវត្តន៍សកម្មភាពខាងលើនេះ ជាបន្តបន្ទាប់ការងារផ្សព្វផ្សាយអប់រំសំដៅធ្វើឱ្យយល់ដឹងពីគ្រឿងញៀន និង ការងារព្យាបាលស្តារនីតិសម្បទាអ្នកញៀន កាន់តែត្រូវបានពង្រឹងនិងពង្រីកដោយមានការចូលរួមយ៉ាងសកម្មពីស្ថាប័នរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិលក្នុង

ស្រុកនានា ។ ការយល់ដឹងពីគ្រឿងញៀនកាន់តែត្រូវបានយល់ជ្រួតជ្រាបដល់ស្រទាប់ប្រជាជន មហាជនក្នុងមូលដ្ឋាន ។ អាណាព្យាបាលអ្នកញៀនមួយចំនួនធំយល់ដឹងពីគុណប្រយោជន៍នៃការផ្តល់សេវាព្យាបាលនិងបានបញ្ជូនកូនទៅកាន់មជ្ឈមណ្ឌល ។ ជាក់ស្តែងក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះគឺឆ្នាំ២០០៦និងឆមាសទី១ឆ្នាំ២០០៧ ចំនួនអ្នកប្រើគ្រឿងញៀនដែលយើងទទួលបានគឺមានការថយចុះ ។ ឆ្នាំ២០០៥ស្ថិតិអ្នកប្រើគ្រឿងញៀនមាន៧.០៧៤នាក់ ។ ឆ្នាំ២០០៦មាន៦.៥០០នាក់ ហើយឆមាសទី១ឆ្នាំ២០០៧នេះចំនួនអ្នកប្រើគ្រឿងញៀនបានបន្តថយចុះ ។

លើសពីនេះទៀត ទោះបីក្រុមឧក្រិដ្ឋជនប៉ុនប៉ងយកកម្ពុជា ធ្វើជាកន្លែងផលិតគ្រឿងញៀនសំយោគលួចលាក់ក្តី ប៉ុន្តែគោលបំណងនេះត្រូវបានសមត្ថកិច្ចធ្វើការបង្រ្កាបទាន់ពេលវេលា ។

## V / ទិសដៅបន្ត :

### ១-ការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ

១.១- បន្តកិច្ចសហការជាមួយ UNODC ក្នុងការអនុវត្តគំរោង KHM/J11 ស្តីពីការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ ។

១.២- បន្តកិច្ចសហការជាមួយUNODCតំបន់ ដើម្បីបង្កើតការិយាល័យUNODCប្រចាំនៅកម្ពុជា។

### ២-កម្មវិធីបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន

២.១- ពង្រឹងសមត្ថភាពក្រុមការងារគ្រឿងញៀន/អេដស៍ ។

២.២- ខិតខំពង្រឹងក្រុមការងារប្រមូលទិន្នន័យអ្នកប្រើគ្រឿងញៀននៅតាមខេត្ត-ក្រុង ។

២.៣- បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន, អង្គការអន្តរជាតិ, អង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីលើកកំពស់ការយល់ដឹងពីគ្រឿងញៀន/អេដស៍ ។

២.៤- បន្តជំរុញការតាមដានការអនុវត្តន៍កម្មវិធីម្ទូល/ស៊ីរ៉ាំង នៅកម្ពុជា ។

២.៥- ត្រៀមការងារអប់រំផ្សព្វផ្សាយលើកកំពស់ការយល់ដឹងជាសាធារណៈ នៅក្នុងពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ ។

### ៣-ការងារអនុវត្តច្បាប់

៣.១- បន្តពង្រឹងយុទ្ធនាការលុបបំបាត់ការដាំដុះដំណាំកញ្ឆា ។

៣.២- លើកកំពស់ការយល់ដឹងអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.៣- បន្តពង្រឹងនិងពង្រីកយន្តការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ដោយកុំព្យូទ័រ (CBT) ។

៣.៤- បន្តសហការជាមួយអង្គការJICAជប៉ុន ក្នុងការអនុវត្តន៍គំរោងទ្វេភាគីស្តីពី ការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។

៣.៥- សហការជាមួយUNODC ក្នុងការអនុវត្តន៍គំរោងI61 តពីគំរោង D91 ។

៣.៦- ធ្វើការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ តាមគំរោងJICAនៅតាមខេត្ត-ក្រុងអាទិភាព ។

៣.៧- បន្តជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ។

**៤-ការងារព្យាបាល**

៤.១- ពង្រឹងសមត្ថភាពក្រុមការងារអនុវត្តគំរោង H83 របស់UNODC ។

៤.២- បន្តកិច្ចសហការអនុវត្តគំរោង H83 របស់UNODC ។

៤.៣- តាមរយៈជំនាញការអាល្លឺម៉ង់ អគ្គលេខាធិការដ្ឋាននឹងបន្តស្វែងរកការគាំទ្រពីដៃគូក្រៅគំរោងក្នុងការរៀបចំសិក្ខាសាលាស្តីពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀន ។

**៥-នីតិកម្ម / ផែនការ**

៥.១- បញ្ចប់ការកសាងផែនការសកម្មភាពជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៨ ។

៥.២- រៀបចំគោលនយោបាយជាតិ ស្តីពីការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

៥.៣- រៀបចំអនុក្រឹត្យ ស្តីពីការរឹបអូសទ្រព្យដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ និងមូលនិធិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**៦-សហប្រតិបត្តិការអន្តរជាតិ**

ត្រៀមចូលរួមក្នុងកិច្ចប្រជុំ :

-ត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគី-ត្រីភាគី កម្ពុជា-វៀតណាម-ឡាវ លើកទី៧ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តសៀមរាប(ថ្ងៃទី០៥-០៧/១២/២០០៧ ។

-ត្រៀមចូលរួមក្នុងកិច្ចប្រជុំទ្វេភាគីមន្ត្រីអនុវត្តច្បាប់ កម្ពុជា-ថៃ លើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ។

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក.លឹម-ធីរ៉ិន

__ចំលងជូន :__

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ

-ឯកឧត្តម អនុប្រធានអចិន្ត្រៃយ៍ អ.ជ.ប.គ.ញ

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

(ដើម្បីជូនជ្រាប)

-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ

-អគ្គលេខាធិការរង អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង

-នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ

## ឈ្មោះជាអក្សរកាត់ និង ឈ្មោះសរសេរពេញ

ដែលមាននៅក្នុងរបាយការណ៍ស្តីពី លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ៩ខែ ឆ្នាំ២០០៧

**អជបគញ** អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**ACCORD** **A**sean **C**hina **C**ooperative **O**peration in **R**esponse to **D**angerous **D**rugs.
កិច្ចសហប្រតិបត្តិការដោយសហការគ្នារវាងសមាជិកអាស៊ាននិងចិនប្រឆាំងគ្រឿងញៀនដែលមានគ្រោះថ្នាក់

**ADEC** **A**sia-pacific **D**rug **E**nforcement **C**onference.
សន្និសីទអន្តរជាតិស្តីពី ការអនុវត្តច្បាប់គ្រឿងញៀន នៅអាស៊ី–ប៉ាស៊ីហ្វិក

**ASOD** **A**sean **S**enior **O**fficials on **D**rug Matters
កិច្ចប្រជុំបញ្ហាគ្រឿងញៀនរបស់មន្ត្រីជាន់ខ្ពស់អាស៊ាន

**ATS** **A**mphetamine **T**ype **S**timulant
អំហ្វេតាមីន ប្រភេទលើកកម្លាំង

**BLO** **B**order **L**iaison **O**ffice
ការិយាល័យទំនាក់ទំនងច្រកទ្វារព្រំដែន

**CBT** **C**omputer **B**ase **T**raining
យន្តការបណ្តុះបណ្តាលដោយកុំព្យូទ័រ

**DEA** **D**rugs **E**nforcement **A**dministration
ការគ្រប់គ្រងកិច្ចការរដ្ឋបាលគ្រឿងញៀន

**D/HA** **D**rugs / **H**iv/Aid
គ្រឿងញៀន/មេរោគអេដស៍, ជំងឺអេដស៍

**FHI** **F**amily **H**ealth **I**nternational
អង្គការសុខភាពគ្រួសារពិភពលោក

**JICA** **J**apan **I**nternational **C**ooperation **A**gency
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ជប៉ុន

**KHANA** **K**hmer **H**IV/**A**IDS **N**GO **A**lliance
អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជម្ងឺអេដស៍

**MOU** **M**emorandum **O**f **U**nderstanding
អនុស្សារណៈនៃការយោគយល់គ្នា

**NACD** **N**ational **A**uthority for **C**ombating **D**rugs
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**NNCC** **N**ational **N**arcotic **C**ontrol **C**ommitee
គណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀន

**ONCB** the **O**ffice of the **N**arcotic **C**ontrol **B**oard
ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀន (ថៃ)

**SOMTC** Asean **S**enior **O**fficials **M**eeting on **T**ransnational **C**rime
កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន

**UNODC** **U**nited **N**ation **O**ffice on **D**rugs and **C**rimes
ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀននិងឧក្រិដ្ឋកម្ម

**WHO** **W**orld **H**ealth **O**rganization
អង្គការសុខភាពពិភពលោក

## លេខគំរោង និង ខ្លឹមសារគំរោង

ដែលមាននៅក្នុងរបាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ៩ខែ ឆ្នាំ២០០៧

| | |
|---|---|
| I 61 | គំរោងស្តីពី យន្តការនៃការរួមបញ្ចូលគ្នាដើម្បីធ្វើឱ្យប្រសើរឡើងថែមទៀតសំរាប់ការិយាល័យទំនាក់ទំនងគ្រឿងញៀននៅព្រំដែន (BLO) ក្នុងតំបន់អាស៊ីបូព៌ា |
| D 91 | គំរោងស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែននៃបណ្តាប្រទេសនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ |
| F 34 | គំរោងស្តីពីសារធាតុគីមីផ្សំនៅអាស៊ី–ប៉ាស៊ីហ្វិក |
| F97 | គំរោងស្តីពីការធ្វើឱ្យប្រសើរឡើងនូវការប្រមូលទិន្នន័យ**ATS** និងប្រព័ន្ធព័ត៌មានគ្រឿងញៀន |
| H 15 | គំរោងស្តីពីការធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូប្រទេសជាសមាជិក **MOU** ក្នុងតំបន់អាស៊ីបូព៌ា |
| H 83 | ស្តីពីការអភិវឌ្ឍន៍ជាមូលដ្ឋានតាមសហគមន៍លើសេវាប្រឹក្សាព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន |
| I 09 | គំរោងស្តីពីការពង្រឹងសមត្ថភាពការព្យាបាលនិងការបង្ការការឆ្លងមេរោគអេដស៍ក្នុងចំណោមអ្នកប្រើគ្រឿងញៀននិងអ្នកនៅក្នុងពន្ធនាគារ |
| G 69 | គំរោងស្តីពីការលើកកំពស់ការយល់ដឹងជាសាធារណៈពីគ្រឿងញៀន |
| I 13 | គំរោងស្តីពីការធ្វើឱ្យប្រសើរឡើងនូវសេវាព្យាបាលយុវជនដែលញៀនថ្នាំ**ATS** |
| KHM/J 11 | គំរោងស្តីពីការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ |